មជ្ឈមណ្ឌលឯកសារកម្ពុជា

# សម្ភាសន៍ជាមួយឈ្មោះ វ៉ន ខន ភេទស្រី អាយុ៤៤ឆ្នាំ
# រស់នៅភូមិអូរស្វាយ ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
# ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣
# សម្ភាសន៍ដោយៈ លឹម ជ័យទ័ត្ត
# ០០:១១:៣៦
# ៧ទំព័រ

ទ័ត្តៈ ជំរាបសួរអ៊ីខ្ញុំសូមជំរាបសួរអ៊ី ខ្ញុំឈ្មោះ លឹម ជ័យទ័ត្ត ហើយខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមានគោលបំណងចងក្រងឯកសារ ចង់សរសេរជាសៀវភៅ ដើម្បីអប់រំក្មេងជំនាន់ក្រោយបានដឹងពីប្រវត្តិសាស្ត្រខ្មែរយើង អ៊ីចឹងដើម្បីដឹងទាល់តែសួរចាស់ៗ ឲ្យចាស់ៗជួយរៀបរាប់ប្រាប់ ។ អ៊ីចឹងខ្ញុំចង់សុំសម្ភាសន៍អ៊ីមួយភ្លែតបានទេអ៊ី?

ខនៈ បាន ។ កន្លែងណាវាចំណាំក៏ចំណាំ កន្លែងណាវាភ្លេចហើយ យូរហើយ ខ្ញុំកាលហ្នឹងនៅក្មេងដែរកាលនោះ ។

ទ័ត្តៈ ចាប់ផ្តើមជំរាបសួរខ្ញុំចង់ស្គាល់ឈ្មោះអ៊ី?

ខនៈ ឈ្មោះ ខន ។

ទ័ត្តៈ ចុះឈ្មោះពេញ ឈ្មោះអីដែរ?

ខនៈ វ៉ន ខន ។

ទ័ត្តៈ ចុះអ៊ីសព្វថ្ងៃមានអាយុប៉ុន្មាន?

ខនៈ ៤៤ ។

ទ័ត្តៈ អ៊ីមានស្រុកកំណើតនៅណា?

ខនៈ អេ៎ មិនមែន៤៤ទេ ខ្ញុំឆ្នាំជូត ។

ទ័ត្តៈ អ៊ីចាំថាកើតនៅឆ្នាំណា?

ខនៈ ឆ្នាំជូត ។

ទ័ត្តៈ ឆ្នាំប៉ុន្មានអ៊ីចាំ?

ខនៈ អត់ផង ។

វណ្ណៈ : ឆ្នាំបារាំង? ឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មាន?

ខនៈ អត់ទេ អត់ចាំ ព្រោះអីម៉ែស្លាប់តាំងពីតូច កំព្រា ។

ទ័ត្តៈ អ៊ីកើតជំនាន់ណាដែរ? ជំនាន់សម្តេចសីហនុ?

ខនៈ	វាទំនង តែមិនដឹងទេ លឺមួយសារកបា៉ល់ហោះគេអូសដៃចូលត្រង់សេ ខ្ញុំថាចូលធ្វើអី ខ្លាចអី ។

ទ័ត្តៈ	ស្រុកកំណើតអ៊ំកាលមុននៅណា?

ខនៈ	នៅស្ទឹងត្រែង ។

ទ័ត្តៈ	នៅភូមិអី ឃុំអី?

ខនៈ	កោះសំពាយ ។

ទ័ត្តៈ	ឃុំ?

ខនៈ	ឃុំកោះសំពាយ ខេត្តស្ទឹងត្រែង ។

ទ័ត្តៈ	ស្រុក? ចាំស្រុក?

ខនៈ	ស្រុកកោះសំពាយដូចគ្នា ។

ទ័ត្តៈ	អ៊ំអាចរៀបរាប់ប្រវត្តិអ៊ីពីក្មេងមកបន្តិចបានទេអ៊ំកាលពីក្មេង?

ខនៈ	មិនចេះរៀបរាប់ទេ ។

ទ័ត្តៈ	ពីក្មេងមកអ៊ំមានបានចូលរៀនទេ?

ខនៈ	រៀនថ្នាក់ទី១-២ ។

ទ័ត្តៈ	ថ្នាក់ទី១-២សម័យដើម?

ខនៈ	ចា៎!

ទ័ត្តៈ	គេហៅទី១២-១១?

ខនៈ	ចុះមកក្រោម ១២-១១ បានដល់ថ្នាក់ទី១គេ មិនមែនពីក្រោមឡើងលើទេ ពីលើចុះមកក្រោម ។

ទ័ត្តៈ	អ៊ីចឹងអ៊ំនៅចាំសម័យហ្នឹង ពេលនៅក្មេងហេតុអីបានអត់បានរៀនទេ? មូលហេតុអីបានឈប់?

ខនៈ	សភាពអត់ស្រួល យើងរត់លូន យើងទៅតាមគេ ។

ទ័ត្តៈ	រត់លូនដោយសារអី?

ខនៈ	មួយសារយើងជំពាក់គេ ហើយសម័យពួកអីៗ យើងមិនដឹងដែលយើងនៅតូច ។

ទ័ត្តៈ	ហ្នឹងធ្វើឲ្យអ៊ំបោះបង់ការសិក្សាហ្នឹងទៅ?

ខនៈ	ចា៎!

ទ័ត្តៈ	ក្រោយពីឈប់រៀនទៅណា?

ខនៈ	រត់ហ្នឹងឯង រត់រហូត ។

ទ័ត្តៈ រត់ទៅណាវិញពេលហ្នឹង?

ខនៈ រត់តាមព្រៃហ្នឹងរហូត ។

ទ័ត្តៈ ព្រៃនៅក្នុងខេត្តស្ទឹងត្រែង-ក្រចេះហ្នឹង?

ខនៈ អត់ទេ ចេញមកឆ្ងាយ តែមិនដឹងស្រុកអីនៅក្នុងព្រៃ នៅស៊ីក្តួច ស៊ីដំឡូង ទៅតាមគេឯង

ទ័ត្តៈ នៅរយៈពេលប៉ុន្មានឆ្នាំដែរអ៊ំ?

ខនៈ គិតទៅ១-២ឆ្នាំ ដូចថាយើងរត់ហូបតែក្តួច អំបិលអត់ឃើញ ។

ទ័ត្តៈ អ៊ំចាំទេថាពេលក្រោយមកទៀតអ៊ំបានទៅដល់ណា?

ខនៈ ធ្លាក់មកហ្នឹងរហូត ។

ទ័ត្តៈ អីចឹង?

ខនៈ ចា៎!

ទ័ត្តៈ ពីព្រៃមកដល់ហ្នឹង?

ខនៈ ចា៎!

ទ័ត្តៈ អ៊ំមានចាំឆ្នាំដែលចូលទៅក្នុងព្រៃហូបក្តួច?

ខនៈ ៧៩ ។

ទ័ត្តៈ ពី៧៩អ៊ំមកហ្នឹងរហូត?

ខនៈ នេះរហូត ១០០៣ មកលើភ្នំ តាមជង់ភ្នំ១០០៣ មករហូត មកធ្លាក់ទល់ដែន ហើយ បានសុខស្រួលអីចេះទៅ បានទៅលេងស្រុកម្តង ។

ទ័ត្តៈ អ៊ំសព្វថ្ងៃមានកូនប៉ុន្មានដែរ?

ខនៈ កូនច្រើនដែរ តែការអស់ហើយ នៅសល់អាពៅមួយ គ្រួសារខ្ញុំពិការ ។

ទ័ត្តៈ អ៊ំមានកូនប៉ុន្មាននាក់ដែរ? ហើយបងគេអាយុប៉ុន្មាន?

ខនៈ បងគេអាយុ៣៣ ។

ទ័ត្តៈ អ៊ំ៤៤អត់ទំនង ។ ចុះអ៊ំការអាយុប៉ុន្មានមានចាំទេ?

ខនៈ អត់ដូចមិនសូវចាំ ព្រោះចូលក្នុងព្រៃ ។

ទ័ត្តៈ ពេលអ៊ំមានផ្ទៃពោះ មានកូនហ្នឹងអាយុប្រហែលប៉ុន្មាន?

ខនៈ អត់ដឹង សូម្បីតែអ្នកស្រុក អ្នកភូមិ អ៊ំទៅដឹងថាបងប្អូន តែដឹទូត ដឹលាអត់ស្គាល់ ទាល់តែ បងប្អូនប្រាប់ត្រូវហៅមីង ត្រូវហៅពូបានដឹង ។

ទ័ត្តៈ អីចឹងការក្រោយបែកខ្មែរក្រហម?

ខនៈ នៅក្នុងព្រៃ ។

ទ័ត្តៈ ឆ្នាំ៧៩ហើយ?

ខនៈ ក្រោយទេ ។

ទ័ត្តៈ អីចឹងមុនឆ្នាំ៧៩អ៊ំអត់បានជួបគាត់ទេ?

ខនៈ អត់ ។

ទ័ត្តៈ ជួបក្រោយបែកទេ?

ខនៈ ក្រោយទើបតែឥឡូវនេះ ស្រុកស្រួលសាន្តត្រាណ ។

ទ័ត្តៈ ពេលនៅក្នុងសម័យខ្មែរក្រហម មុនឆ្នាំ៧៩ អ៊ំនៅណា?

ខនៈ នៅនេះ ខ្ញុំនៅ១០០៣ រត់ក្នុងព្រៃនោះ ។

ទ័ត្តៈ នៅក្នុងហ្នឹងគេឲ្យធ្វើអី?

ខនៈ អត់មានធ្វើអីទេ នៅក្នុងព្រៃទេៗ ហើយជីកដំឡូង ជីកក្ដួចអត់ហ៊ានចូលភូមិ ។

ទ័ត្តៈ ហ្នឹងក្រោយបែក៧៩ទេ?

ខនៈ ចា៎! ក្រោយ៧៩ គេថាសភាពអត់ស្រួលហើយគេដេញចាប់ ទៅតាមគេ ខ្ញុំខ្លាច ខ្ញុំដឹងអី ។

ទ័ត្តៈ ពេលសម័យឆ្នាំ ក្រោយពេលទំលាក់សម្ដេចសីហនុ អ៊ំមាននៅចាំទេ?

ខនៈ អត់ទេ ។

ទ័ត្តៈ អ៊ំអត់ដឹង?

ខនៈ អ្នកព្រៃ ឲ្យអ៊ំនិយាយរឿងហ្នឹងអត់ចេះទេ មានតែចា៎ រហូត ព្រៃសុទ្ធ ។

ទ័ត្តៈ ពេលអ៊ំរត់ចូលព្រៃពីស្រុកកំណើតហ្នឹង អ៊ំរត់ចូលប៉ុន្មានឆ្នាំ?

ខនៈ មួយឆ្នាំជាងមើលទៅ បានឡើងមកលើភ្នំ នៅជាមួយគេឯង យូរៗគេនាំចុះមកដីខ្មែរវិញ

ទ័ត្តៈ ភ្នំអីគេអ៊ំ?

ខនៈ ភ្នំដងរែក ។

ទ័ត្តៈ នៅលើភ្នំហ្នឹងដីខ្មែរដែរ?

ខនៈ ដីខ្មែរ ។

ទ័ត្តៈ នៅលើភ្នំហ្នឹងប្រកបរបរយ៉ាងម៉េច?

ខនៈ អូនអើយមានស្អី មានតែជីកដំឡូង នាំគ្នាហូប ជីកក្ដួច សូម្បីតែអំបិលមិនឃើញមួយគ្រាប់ផង ។

ទ័ត្តៈ អ៊ំអត់បានចូលរួមតស៊ូ?

ខនៈ អត់ទេ ។

ទ័ត្តៈ ផុតពីហ្នឹងមកចូលកសិកម្មសុទ្ធសាធ?

ខនៈ ចាំ! សុទ្ធសាធ រាល់ថ្ងៃក៏អ៊ីក្រ អត់មាន ។

ទ័ត្តៈ រាល់ថ្ងៃអ៊ីមានចៅប៉ុន្មាននាក់ហើយសព្វថ្ងៃ?

ខនៈ សព្វថ្ងៃមានចៅ២ ។

ទ័ត្តៈ កូនប៉ុន្មាននាក់បានចៅ២?

ខនៈ គេអត់ទាន់យកគ្រួសារកូនប្រុស ។

ទ័ត្តៈ សរុបទាំងអស់ប៉ុន្មាន?

ខនៈ ៨ ។

ទ័ត្តៈ ច្រើនគួរសម តែទើបតែបានចៅ២ ។

ខនៈ ចាំ! ចំអ្នកអត់ ។

ទ័ត្តៈ តិចទៀតពួកគាត់ចិញ្ចឹមវិញ?

ខនៈ បានកូនចិញ្ចឹមអរ អូនឯងអត់ស្តាប់ ពាក្យចាស់ថាកូន១០ ចិញ្ចឹមបានទាំងអស់ តែឲ្យកូនចិញ្ចឹមម៉ែ ឪវិញ មិនបានផង មិនស្មើរម៉ែផង ។

ទ័ត្តៈ អ៊ីប្រុសគាត់អញ្ជើញទៅយូរហើយ?

ខនៈ ទៅយូរហើយ អត់ទាន់ឃើញមក ។

ទ័ត្តៈ អ៊ីដឹងថាស្ថានណាគាត់អាចមកវិញ?

ខនៈ យូរដែរ កណ្តាលភូមិ ។

ទ័ត្តៈ ទៅក្រោយចេះទៀត?

ខនៈ ចាំ!

ទ័ត្តៈ ទៅក្រោយមានភូមិគេទៀត?

ខនៈ មានភូមិគេ នៅក្នុងភូមិគេ ។

ទ័ត្តៈ មានចាស់ៗច្រើនទេអ៊ី?

ខនៈ ច្រើន ។

ទ័ត្តៈ ចង់សួរពួកគាត់ដែរ ។

ខនៈ ទៅពីនេះទៅមានម្នាក់ ផ្ទះតូចទេលក់ឥវ៉ាន់ ចូលផ្លូវហ្នឹង ។

ទ័ត្តៈ ផ្លូវដែលអ៊ីដើរម៉ិញ?

ខនៈ ទេ នោះ កន្លែងឃើញផ្លូវបំបែក ផ្លូវឡាន ។

ទ័ត្តៈ ចុះផ្លូវក្រោយដើរបានទេ?

ខនៈ ដើរអត់អីទេ ។

ទ័ត្តៈ	ដើរតាមនេះមានផ្លូវគេទេ?

ខនៈ	មាន យើងទៅដល់ស្រែគាត់ ។

ទ័ត្តៈ	អីចឹងដើរពីនេះដើរតាមវាលស្រែ?

ខនៈ	នេះតាមវាលស្រែនេះ ។

ទ័ត្តៈ	ហើយឡើងទៅណាវិញ?

ខនៈ	ឡើងកាច់ទៅនោះ មានផ្លូវតែមួយទេ កុំទៅលិច ។

ទ័ត្តៈ	ទៅខាងត្បូងវិញ?

ខនៈ	ចាំ! កាច់មកកើតមក ។

ទ័ត្តៈ	ភាគច្រើនចាស់ៗនៅនេះ?

ខនៈ	ចាំ!

ទ័ត្តៈ	គាត់សុទ្ធតែអ្នកតស៊ូ?

ខនៈ	ចាំ! អ្នកតស៊ូ មានម្នាក់ ហើយប្ដីគាត់ទៅចេះលើសឈាម គាត់ម្នាក់គាត់អ្នកតស៊ូដែរ ។

ទ័ត្តៈ	សព្វថ្ងៃគាត់ធ្វើអី?

ខនៈ	គាត់តស៊ូ អាំប្រុសនោះអត់ចេះនិយាយទេ និយាយអត់ចេញទេ ផាប់មួយចំហៀងខ្លួន ។

ប្រុញៈ	ឈ្មោះអីគេ?

ខនៈ	បើប្រពន្ធគាត់បានចេះនិយាយ ។

ទ័ត្តៈ	ប្រពន្ធគាត់អ្នកតស៊ូដែរ?

ខនៈ	ចាំ! អ្នកតស៊ូដូចគ្នា ។

ទ័ត្តៈ	ចុះគាត់ធ្វើអីដែរសម័យមុនអាំមានដឹង?

ខនៈ	អត់ដឹងទេ របស់គេផ្សេង ដូចថាមួយក្រុមៗ ហើយ១០-២០នាក់មួយដុបៗ ។

ទ័ត្តៈ	នៅក្រោយមានភូមិសុទ្ធតែចាស់ៗ?

ខនៈ	ចាំ!

ទ័ត្តៈ	អីចឹងសុំសួរអីចឹងគាត់អត់ថាអី?

ខនៈ	ចាំ! មានទៅថាអី គ្រាន់តែយើងសុំសម្ភាសន៍ ប្រាប់ដូចអាំ បើគាត់ចង់ដឹងសម្ភាសន៍ទៅធ្វើអី យើងប្រាប់គាត់ ។

ទ័ត្តៈ	ពីនេះទៅដើរទៅឆ្ងាយទេអាំ?

ខនៈ	អត់ឆ្ងាយទេ ។

ទ័ត្តៈ	ប៉ុន្មាននាទីដែរ?

ខនះ អ៊ូ! មិនបាន១០នាទីផង ៥នាទី ។

ទ័ត្តះ ត្រឹមនេះមើលឃើញ?

ខនះ ចា៎! ទៅនេះ ទៅតាមផ្ទះគាត់នេះ ឃើញផ្លូវនេះទៅអីចឹង កាច់ទៅចេះ ដើរតាមភូមិ សុទ្ធតែអ្នកចាស់ៗ ។

ទ័ត្តះ អីចឹងខ្ញុំប្រហែលជាអត់មានអីសួរអ៊ុំទៀតទេ អ៊ុំរៀបរាប់ច្រើនដែលគួរសម ។

ខនះ អូនអើយត្រចៀកអ៊ុំធ្ងន់ ។

ទ័ត្តះ អីចឹងគិតជំរាបលាអ៊ុំទៅសួរអ្នកក្រោយ ។

ខនះ ចា៎!

ទ័ត្តះ អរគុណច្រើនអ៊ុំ ។

**ចប់**